**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០៣ . សរ**

# សារាចរ

## ស្តីពី

## វិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង និង ត្រួតពិនិត្យការធ្វើអាជីវកម្មសម្ភារៈកសិកម្ម

កន្លងមករាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងសម្ភារៈកសិកម្មរួមមាន : ជីគីមី ថ្នាំកសិកម្ម គ្រាប់ពូជ និង បំណែកពូជដំណាំ បសុឱសថ ចំណីសត្វ និង ចំណីបន្ថែម ដើម្បីសម្រួលដល់អ្នកប្រើប្រាស់ និង កសិករឱ្យមានសមត្ថភាពយល់ដឹងក្នុងការប្រើប្រាស់សម្ភារៈកសិកម្មទាំងអស់ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព តាមរយៈលិខិតបទដ្ឋាននានាជាអាទិ៍ ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និង សេវា ដែលប្រកាសឱ្យប្រើតាមរយៈព្រះរាជក្រម លេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ អនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពីបមាណី និង ការគ្រប់គ្រងសម្ភារៈកសិកម្ម សារាចរណែនាំលេខ ៣៤៥ សរណន.កសក ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការអនុវត្តអនុក្រឹត្យ លេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពីបមាណី និង ការគ្រប់គ្រងសម្ភារៈកសិកម្ម និង បណ្តាប្រកាស សេចក្តីណែនាំអនុវត្តផ្សេងទៀតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

ទោះជាមានមូលដ្ឋានលិខិតបទដ្ឋានច្បាប់សម្រាប់គ្រប់គ្រងសម្ភារៈកសិកម្ម និង មានវិធានការអនុវត្តន៍ដោយសមត្ថកិច្ចពាក់ព័ន្ធហើយក្តី រាជរដ្ឋាភិបាលនៅតែសង្កេតឃើញថាការគ្រប់គ្រង និង ការត្រួតពិនិត្យលើការនាំចូល ការផលិត ការកែច្នៃ ការចែកចាយ និង ការលក់ដូរសម្ភារៈកសិកម្មនៅមិនទាន់មានប្រសិទ្ធភាពពេញលេញនៅឡើយ ដូចជានៅមានការហូរចូលដោយល្មើសច្បាប់នូវជីគីមី ថ្នាំកសិកម្ម និង សម្ភារៈកសិកម្ម

ផ្សេងទៀតដែលងាយបង្កគ្រោះថ្នាក់។ល។ ទន្ទឹមនេះមានជនមួយចំនួនបានធ្វើអាជីវកម្មកេងប្រវ័ញ្ច តាមរយៈការផលិតកែច្នៃជីគីមីក្លែងគុណភាព ឬ លាយផ្សំដោយគ្មានមូលដ្ឋានបច្ចេកទេសត្រឹមត្រូវ ឬ ក្លែងសំបកវេចខ្ចប់ និង បានធ្វើការលក់ ចែកចាយតាមរយៈឈ្មួញកណ្តាល ដោយដឹកជញ្ជូនដល់ភូមិ ឃុំ ក្រោមរូបភាពលក់បណ្តាក់ ដោយយកការប្រាក់ទាប ឬ លក់ក្នុងតម្លៃថោក។ សកម្មភាពអសីលធម៌នេះបាននាំមកនូវសម្ពាធកាន់តែធ្ងន់ធ្ងរថែមទៀត ចំពោះកសិករក្រីក្រព្រមទាំងបាននាំមកនូវផលប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅជនបទ ដែលជាទង្វើផ្ទុយទៅនឹងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

ឆ្លងតាមសកម្មភាពដ៏គ្រោះថ្នាក់នេះ ដើម្បីពង្រឹងឡើងវិញនូវប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និង ត្រួតពិនិត្យការធ្វើអាជីវកម្មសម្ភារៈកសិកម្មឱ្យបានត្រឹមត្រូវ ធានានូវបមាណីគុណភាពដល់អ្នកប្រើប្រាស់ រក្សានូវសុវត្ថិភាពស្បៀង សុខភាពសាធារណៈ ក្សេត្របរិស្ថាន និង រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់កសិករ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការបន្ថែមដូចខាងក្រោម :

១-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវបន្តអនុវត្តការផ្សព្វផ្សាយ អប់រំណែនាំអំពីគ្រោះថ្នាក់ និង ហានិភ័យដែលអាចបង្កឡើងដោយការប្រើប្រាស់សម្ភារៈកសិកម្ម។

២-ក្រសួងព័ត៌មានត្រូវជួយតាមដាន ត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុកលើការផ្សព្វផ្សាយពាណិជ្ជកម្មស្តីពីសម្ភារៈកសិកម្មជាអាទិ៍ ជីគីមី ថ្នាំកសិកម្ម ចំណីសត្វដែលនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាដោយល្មើសច្បាប់ គ្មានការត្រួតពិនិត្យ និង គ្មានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

៣-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវសហការជាមួយក្រសួងព័ត៌មាន និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដើម្បី :

-ធ្វើការផ្សព្វផ្សាយ អប់រំដល់អាជីវករសម្ភារៈកសិកម្មឱ្យទទួលយកវិធានការបច្ចេកទេសជាចាំបាច់ និង ត្រូវស្នើសុំលិខិតអនុញ្ញាតពីសមត្ថកិច្ចកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្របតាមនីតិវិធី និង បទប្បញ្ញត្តិច្បាប់ជាធរមាន។

-ធ្វើការផ្សព្វផ្សាយ អប់រំណែនាំកសិករក្នុងមូលដ្ឋាន ឱ្យមានយល់ដឹង និង ត្រូវមានស្មារតីប្រុងប្រយ័ត្នអំពីគ្រោះថ្នាក់ និង ហានិភ័យ ដែលអាចបង្កឡើងដោយ

សម្ភារៈកសិកម្ម ដោយប្រើប្រាស់សម្ភារៈកសិកម្មណាដែលធានាគុណភាពច្បាស់លាស់ ហើយនៅលើសំបកវេចខ្ចប់មានស្លាកសញ្ញាព័ត៌មានបច្ចេកទេសត្រឹមត្រូវជាអក្សរខ្មែរដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នៅក្រោយពេលនាំចូល និង នៅពេលចរាចរចែកចាយ ប្រើប្រាស់។

៤-ទីចាត់ការគយ និង រដ្ឋាករ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចាំបាច់ត្រូវជំរុញការអនុវត្តអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ រួមមានការបង្កើតកិច្ចព្រមព្រៀងអន្តរស្ថាប័ន ពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យលើទំនិញនាំចេញនាំចូល ជាពិសេសសម្ភារៈកសិកម្ម។

៥-សមត្ថកិច្ចគយ និង រដ្ឋាករ សមត្ថកិច្ចកាំកុងត្រូល និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៅតាមបណ្តាច្រកព្រំដែន រួមទាំងអាជ្ញាធរដែនដីដែលមានព្រំដែនជាប់ប្រទេសជិតខាងត្រូវពង្រឹងការត្រួតពិនិត្យការនាំចូលសម្ភារៈកសិកម្មគ្រប់ប្រភេទ ជាពិសេសត្រូវចាត់វិធានការបន្ទាន់ចំពោះការហូរចូលនូវសម្ភារៈកសិកម្មក្លែងគុណភាព និង ខូចគុណភាព សម្ភារៈកសិកម្មនាំចូលដោយគ្មានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឬ មានប្រភពល្មើសច្បាប់ផ្សេងទៀត ព្រមទាំងចាត់វិធានការផងដែរចំពោះការហូរចូលសម្ភារៈកសិកម្មល្មើសច្បាប់តាមច្រករបៀងដោយប្រើរូបភាពតូចៗ។

៦-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវចាត់វិធានការចាំបាច់នានាជាបន្ទាន់ សំដៅពង្រឹងការអនុវត្តច្បាប់ជាធរមាន លើការធ្វើអាជីវកម្មសម្ភារៈកសិកម្ម ជាពិសេសត្រូវចាត់វិធានការបង្ក្រាបចំពោះមូលដ្ឋានអាជីវកម្មដែលនាំចូល ផលិត កែច្នៃ ចែកចាយសម្ភារៈកសិកម្មក្លែងគុណភាព និង ខូចគុណភាព ឬ មានប្រភពនាំចូលដោយល្មើសច្បាប់។

៧-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និង អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវសហការឱ្យបានល្អប្រសើរជាមួយសមត្ថកិច្ចកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងការអនុវត្តច្បាប់ និង បង្ក្រាបរាល់អំពើល្មើសច្បាប់ក្នុងការធ្វើអាជីវកម្មលក់ដូរសម្ភារៈកសិកម្ម ជាពិសេសត្រូវចាត់វិធានការដ៏តឹងរ៉ឹងលុបបំបាត់ការធ្វើអាជីវកម្ម ឬ ការបង្កើតមូលដ្ឋានអាជីវកម្មសម្ភារៈកសិកម្មក្លែងគុណភាពនៅក្នុងមូលដ្ឋានខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និង ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមព្រះរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
-គ្រប់សាលាខេត្ត-ក្រុង
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ